# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្វាសនៅចំប៉ា
# ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៨

*ធ្វើយ៉ាងណាដើម្បីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់*

អត្ថបទទី១៖ អគ ១៧,២២-២៤
អត្ថបទទី២៖ ២ករ ៥,៦-១០
ដំណឹងល្អ៖ មក ៤,២៦-៣៤

បងប្អូនជាទីស្រឡាញ់!

នៅថ្ងៃនេះដែលយើងជួបជុំគ្នា ដើម្បីកោតសរសើរព្រះជាម្ចាស់ ជាពិសេសដើម្បីទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកលើប្អូនទាំង៧០នាក់ យើងត្រូវតែគិតពិចារណាអំពីជីវិតរបស់យើង។ ជីវិតរបស់យើងមានគោលដៅអ្វីខ្លះ? ជីវិតរបស់យើងមានគោលបំណងអ្វីខ្លះ? នៅពេលយើងសួរដល់ប្អូនៗមូលហេតុអ្វីយើងចង់ទទួលព្រះវិញ្ញាណដ៏វិសុទ្ធ? ដោយសារគេចង់ទៅជាគ្រីស្តបរិស័ទក្លាហាន ដោយសារគេចង់ពោរពេញដោយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដោយសារគេចង់មានជីវិតយ៉ាងពេញលក្ខណៈ ដោយសារគេចង់ទៅជាមនុស្សយ៉ាងអស្ចារ្យ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដែរលជាសេចក្តីស្រឡាញ់ ដែលជាកម្លាំងរបស់ព្រះជាម្ចាស់។ សម្រាប់យើងទាំងអស់គ្នាដែលជាគ្រីស្តបរិស័ទ ពីថ្ងៃដែរលយើងបានទទួលពិធីជ្រមុជទឹក យើងដឹងថាយើងជាសាវ័ករបស់ព្រះគ្រីស្ត យើងជាមិត្តសំឡាញ់របស់ព្រះយេស៊ូ ប៉ុន្តែជួនកាលយើងអត់ចេះគិតឃើញ ដល់គោលបំណងយ៉ាងធំនៃជីវិតរបស់យើង ដល់គោលដៅយ៉ាងពិសេសនៃជីវិតរបស់យើង។ ឲ្យយើងគិតពីមួយថ្ងៃទៅមួយថ្ងៃ រៀនសូត្រ មើលកូន រកស៊ី មើលសុខភាពពេលយើងឈឺ ខិតខំតស៊ូនៅក្នុងជីវិតនៅពេលមានបញ្ហា។ ប៉ុន្តែ ជីវិតរបស់យើងប្រចាំថ្ងៃ ជាអ្នកដែរលទៅរៀន ជាអ្នករកស៊ី ជាឪពុកម្តាយ ជាតាយាយ ជាអ្នកជំងឺ ជាអ្នកដែលធូរធារ ជាអ្នកក្រីក្រ ជាគ្រីស្តបរិស័ទ ជីវិតរបស់យើងប្រចាំថ្ងៃ មានអត្ថន័យលុះត្រាតែយើងចេះមើលគោលបំណងមួយយ៉ាងពិសេស។

ថ្ងៃនេះ នៅក្នុងអត្ថបទទី២ យើងបានស្តាប់គោលបំណងរបស់យើងជាគ្រីស្តបរិស័ទ គោលដៅនៃជីវិតរបស់យើងជាគ្រីស្តបរិស័ទ យើងជាបូជាចារ្យក្តី យើងជានិស្សិតទេវវិទ្យាល័យក្តី យើងជាគ្រីស្តបរិស័ទក្តី យើងមានគោលបំណងតែមួយ "**ទោះបីយើងស្ថិតនៅក្នុងរូបកាយនេះ ឬត្រង់ឃ្លាតឆ្ងាយពីរូបកាយនេះក្តី យើងមានបំណងតែមួយ ធ្វើយ៉ាងណាឲ្យតែធ្វើគាប់ព្រះហឫទ័យព្រះអង្គ**" ធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះជាម្ចាស់ពេញចិត្តលើយើង ធ្វើយ៉ាងម៉េចឲ្យព្រះជាម្ចាស់សប្បាយចិត្តដោយសារយើង នេះជាគោលបំណងនៃជីវិតរបស់យើង។ នៅពេលយើងនឹកឃើញនេះ ជីវិតរបស់យើងអាចទៅជាជីវិតថ្មីមែនទែន យើងមិនគិតអំពីតួនាទីរបស់យើងនៅក្នុងសង្គម ដូចខ្ញុំនិយាយ សិស្សសាលា អ្នករកស៊ី មេគ្រួសារ យាយតា អ្នកជំងឺ អ្នកមាន អ្នកក្រ យើងមិនគិតនេះទេ ប៉ុន្តែយើងគិតពីគោលបំណងយ៉ាងធំនៃជីវិតរបស់យើង ឲ្យយើងបំពេញតួនាទីរបស់យើងនៅក្នុងសង្គម ឲ្យយើងបំពេញតួនាទីរបស់យើងនៅក្នុងព្រះសហគមន៍ ដោយនឹកឃើញនេះធ្វើយ៉ាងណាដើម្បីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ធ្វើយ៉ាងណាឲ្យព្រះជាម្ចាស់សប្បាយចិត្ត។ កូនកតញ្ញូជាកូនដឹងគុណឪពុកម្តាយ ដែលយកចិត្តទុកដាក់លើឪពុកម្តាយ ដែលស្រឡាញ់ឪពុកម្តាយ ដែលខិតខំឲ្យ

ឪពុកម្ដាយសប្បាយចិត្ត ដោយសារកូនល្អជាកូនដែលធ្វើយ៉ាងណាឲ្យឪពុកម្ដាយសប្បាយចិត្ត មិនធ្វើឲ្យឪពុកម្ដាយឈឺចិត្ត។ ទទួលទឹកព្រះពរពីព្រះជាម្ចាស់ត្រូវធ្វើយ៉ាងម៉េចដើម្បីឲ្យឪពុកម្ដាយសប្បាយចិត្ត។ ប៉ុន្តែយើងធ្វើយ៉ាងម៉េចដើម្បីឪពុកម្ដាយយើងពេញចិត្តនឹងយើង ទោះបីយើងតូចក៏ដោយ យើងចាស់ក៏ដោយនៅពេលឪពុកម្ដាយនៅលើផែនដីនេះ យើងខិតខំឲ្យឪពុកម្ដាយមានអំណរសប្បាយនិងសេចក្ដីសុខ។

តាមប្រពៃណីខ្មែរ នៅពេលយើងចាប់ផ្ដើមធ្វើការមានប្រាក់ខែ អត់ទាន់មានគ្រួសារផ្ទាល់ ប្រាក់ខែរបស់យើងដើម្បីជួយឪពុកម្ដាយ។ នៅពេលយើងមានការងារធ្វើ យើងខិតខំធ្វើយ៉ាងម៉េចដើម្បីឪពុកម្ដាយផ្ទះមួយយ៉ាងសមរម្យតាមជនបទ យើងធ្វើយ៉ាងម៉េចដើម្បីមើលឪពុកម្ដាយរបស់យើង ដែលបានតស៊ូអស់មួយជីវិតដើម្បីកូនទៅជាអ្នកធំពេញវ័យម្នាក់ យើងធ្វើយ៉ាងម៉េចអាចឲ្យឪពុកម្ដាយមានសេចក្ដីសុខ មានម្ហូបអាហារគ្រប់គ្រាន់ មានថ្នាំព្យាបាលផ្សេងៗ។ ដូចគ្នានិងព្រះជាម្ចាស់ យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ យើងធ្វើយ៉ាងម៉េចឲ្យព្រះជាម្ចាស់សប្បាយចិត្តជាមួយយើង ពេលយើងស្ដាប់នេះយើងយល់ ជីវិតរបស់យើងមានអត្ថន័យណាស់ ដោយសារយើងដឹងអ្វីដែលខ្ញុំធ្វើ អ្វីដែរខ្ញុំនិយាយ សំដីរបស់ខ្ញុំ ការប្រព្រឹត្តរបស់ខ្ញុំ ធ្វើយ៉ាងម៉េចឲ្យព្រះជាម្ចាស់ពេញចិត្តនិងសប្បាយចិត្ត។ បន្តិចទៀតបងប្អូន ទទួលព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងទៅជាមនុស្សថ្មី៖

**ទីមួយ ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យមានប្រាជ្ញាឈ្លៀសវៃ** ឲ្យយើងចេះគិតឃើញវែងឆ្ងាយដូចព្រះជាម្ចាស់តែម្ដង ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងពិចារណាដឹងខុសដឹងត្រូវ ដឹងល្អដឹងអាក្រក់ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំយើងឲ្យដឹងសេចក្ដីពិត កុំឲ្យយើងវង្វេងផ្លូវនៅក្នុងជីវិត ដោយដើរតាមព្រះក្លែងក្លាយដែលជាលុយ ដែលជាលោកីយ៍ ណែនាំឲ្យយើងវង្វេងច្រើននៅក្នុងសង្គម។

**ទីពីរ ព្រះវិញ្ញាណដ៏វិសុទ្ធផ្ដល់ឲ្យមានយោបល់ល្អ** កុំឲ្យយើងជាមនុស្សដែលប្រព្រឹត្តអំពើអាក្រក់យោយៅ សាហាវ។ ផ្ទុយទៅវិញ ឲ្យយើងមានយោបល់ល្អដើម្បីរស់នៅក្នុងជីវិតផ្ទាល់ខ្លួន។

**ទីបី ព្រះវិញ្ញាណដ៏វិសុទ្ធផ្ដល់ឲ្យទៅជាមនុស្សអង់អាច** ទៅជាមនុស្សដែលពោរពេញដោយសេចក្ដីក្លាហាន ដើម្បីបង្ហាញដល់អ្នកដទៃនៅពេលគេដើរតាមផ្លូវខុស នៅពេលគេដើរតាមផ្លូវល្អយើងសរសើរគេនឹងដើរជាមួយគេថែមទៀត។

ដូច្នេះដើម្បីទៅជាមនុស្សម្នាក់ មានន័យថាកូនរបស់ព្រះជាម្ចាស់ បុត្រធីតារបស់ព្រះជាម្ចាស់ បុត្រាបុត្រីរបស់ព្រះជាម្ចាស់ដ៏ល្អប្រសើរ ដើម្បីណែនាំឲ្យព្រះជាម្ចាស់សប្បាយចិត្ត និងមានអំណរសប្បាយដោយសារយើង យើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែរជាកម្លាំងមួយយ៉ាងពិសេស ដោយដឹងថា "**ដ្បិតយើងទាំងអស់គ្នា ជាមនុស្សក្មេងក្ដី ចាស់ក្ដី យើងត្រូវទៅឈរនៅមុខទីកាត់ក្ដីរបស់ព្រះគ្រីស្ដដើម្បីឲ្យម្នាក់ៗទទួលផលតាមអំពើដែលខ្លួនបានប្រព្រឹត្ត ទោះបីជាអំពើនោះល្អ ឬអាក្រក់ក្ដី កាលពីនៅរស់នៅក្នុងរូបកាយនេះនៅឡើយ**" នេះជាជីវិតរបស់យើង គោលបំណងណែនាំឲ្យព្រះជាម្ចាស់ពេញចិត្ត ប៉ុន្តែថ្ងៃចុងក្រោយនៃជីវិត

របស់យើង យើងជួបជាមួយព្រះជាម្ចាស់នៅទីកាត់ក្តី នៅតុលាការរបស់ព្រះជាម្ចាស់ ដើម្បីស្តាប់សំណួររបស់ព្រះជាម្ចាស់តែមួយ **កូនអើយ! តើកូនបានស្រឡាញ់ខ្ញុំនិងបងប្អូនឯទៀតៗឬទេ? កូនអើយ! តើបានយកចិត្តទុកដាក់ធ្វើជាមនុស្សល្អសម្រាប់អ្នកដទៃ និងសម្រាប់ផ្ទាល់ខ្លួនឬទេ?** អំពើល្អដែលយើងបានធ្វើណែនាំឲ្យយើងអាចឈរនៅមុខព្រះជាម្ចាស់ដោយមានកម្លាំងពេញខ្លួន អំពើអាក្រក់ដែលយើងបានធ្វើណែនាំឲ្យយើងខ្មាស់នឹងព្រះជាម្ចាស់ ដូចអាដាំនិងអេវ៉ាពីដើម ដោយសារយើងនៅមុខព្រះជាម្ចាស់នៅទីកាត់ក្តីរបស់ព្រះជាម្ចាស់ នៅពេលនោះដូចយើងនៅខ្លួនទទេ អត់មានអីលាក់ ព្រះជាម្ចាស់មើលឃើញទាំងអស់។

ដូច្នេះអ្វីដែរលយើងបានធ្វើល្អ ព្រះជាម្ចាស់សរសើរយើង អ្វីដែរលយើងបានធ្វើអាក្រក់ព្រះជាម្ចាស់មិនសប្បាយចិត្ត ប៉ុន្តែយើងដឹងថាព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណាប្រណីសណ្តោស ព្រះជាម្ចាស់មិនលះបង់ចោលមនុស្សដែលធ្វើអំពើបាប។ ដូច្នេះជីវិតរបស់យើងខុសគ្នាមែនទែន ជាមូលហេតុគ្រីស្តបរិស័ទពោពេញដោយអំណរសប្បាយ ដោយសារពេលយើងទទួលស្គាល់អំពើបាបរបស់យើង ពេលយើងសម្រេចចិត្តថាយើងកែប្រែចិត្តគំនិត នៅពេលយើងទទួលអគ្គសញ្ញាលើកលែងទោសពីលោកឪពុក នៅពេលនោះបាបរបស់យើងអស់ហើយ។ ដូច្នេះយើងមិនត្រូវការធ្វើអំពើល្អច្រើន ដើម្បីលុបបាប ដោយសារយើងពឹងផ្អែកលើព្រះហឫទ័យប្រណីសណ្តោស លើព្រះអំណោយទានធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលលើកលែងទោសឲ្យមនុស្សដែលធ្វើខុសនឹងព្រះហឫទ័យព្រះអង្គ។ ដូច្នេះជីវិតរបស់យើង យើងដឹងហើយដោយសារព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងទទួលថ្ងៃនេះ ដោយសារគោលបំណងរបស់យើងធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះជាម្ចាស់ពេញចិត្ត ដោយដឹងថាថ្ងៃចុងក្រោយគេសួរខ្ញុំតើខ្ញុំបានស្រឡាញ់ឬអត់? តើខ្ញុំបានធ្វើអ្វីខ្លះដល់បងប្អូនឯទៀតៗ? តើខ្ញុំបានលើកទឹកចិត្តឬមើលងាយ? តើយើងបានលើកតម្កើនឬជិះជាន់បងប្អូនឯទៀតៗ? នៅពេលនោះព្រះជាម្ចាស់វិនិច្ឆ័យយើងមែន ប៉ុន្តែព្រះជាម្ចាស់នឹកឃើញ ប៉ុន្មានលើកប៉ុន្មានសារយើងបានទទួលស្គាល់អំពើបាបរបស់យើង ទទួលលារលើកលែងទោសពីព្រះអង្គដើម្បីធ្វើដំណើរតទៅទៀត។

សន្តីតេរេសានៃព្រះកុមារយេស៊ូបាននិយាយថា "**ខ្ញុំដឹងហើយ ទោះបីខ្ញុំធ្វើអំពើបាបធំជាងគេដែលអាចធ្វើបាននៅក្នុងពិភពលោកទាំងមូល ព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំតទៅទៀត លើកលែងតែអំពើបាបប្រឆាំងនឹងព្រះវិញ្ញាណដ៏វិសុទ្ធ**"។ ព្រះជាម្ចាស់យាងមកដើម្បីសាបព្រោះពូជល្អិតតូចៗ ដែលយើងមើលមិនឃើញប៉ុន្តែពូជនេះលូតលាស់រីកចម្រើន ដើម្បីធ្វើជាដើមឈើមួយយ៉ាងធំដែលមានម្លប់យ៉ាងត្រជះត្រចង់ ដែលណែនាំឲ្យបក្សាបក្សីទាំងឡាយអាចបង្កើតសំបុករបស់គេ ដើម្បីពោរពេញដោយសេចក្តីសុខនឹងអំណរសប្បាយ នេះជាព្រះសហាគមន៍របស់យើង។ ព្រះសហាគមន៍របស់យើង ធ្វើដោយពូជយើង យើងម្នាក់ៗជាពូជល្អិតតូចនៅក្នុងមនុស្សលោកពិតមែន តូចនៅក្នុងសង្គមកម្ពុជាពិតមែន ដោយសារយើងជាគ្រីស្តបរិស័ទរាប់ពាន់នាក់នៅក្នុងដប់ប្រាំ ដប់ប្រាំមួយលាននាក់។ ដូច្នេះយើងជាពូជល្អិតតូចបំផុត ប៉ុន្តែតូចនេះ បន្តិចម្តងៗរីកចម្រើនទៅជាដើមឈើមួយដែលមានមែកច្រើន មានស្លឹកខៀវខ្ចីយ៉ាងច្រើនណែនាំឲ្យបក្សាបក្សីមកជ្រកដោយសេចក្តីសុខសាន្ត។

ពិតមែនព្រះសហគមន៍របស់យើង ជាកន្លែងមួយដែលយើងមានអំណរសប្បាយជួបជុំគ្នា ដោយដឹងថាយើង ជាមនុស្សដែលមានអំពើបាបមែនប៉ុន្តែព្រះជាម្ចាស់លើកលែងទោសឲ្យយើង ដោយដឹងថាយើងជាគ្រួសារមួយយ៉ាងកក់ក្តៅ។ យើងជួបជុំគ្នា ដូចមហាគ្រួសារមួយដែលមានគ្រីស្តបរិស័ទតិចណាស់ ប៉ុន្តែយើងមានកូនក្មេង យើងមានយុវជន យើងមានតាយាយពុទ្ធបរិស័ទច្រើន គេមកដោយសារគេចង់ស្តាប់បន្ទូលដំណឹងល្អ ដោយសារគេមានអារម្មណ៍ដូចបក្សាបក្សី ដូចសត្វកក់ដែលមកដើម្បីជួបជុំគ្នា គេសប្បាយចិត្ត ដោយសារគេរកឃើញគ្រួសារមួយដែលណែនាំឲ្យមានភាពកក់ក្តៅ។ កុំឲ្យយើងជាគ្រួសារតែមួយនៅពេលយើងចូលព្រះវិហារ ប៉ុន្តែនៅក្នុងជីវិតប្រចាំថ្ងៃឲ្យយើងចេះមើល ឲ្យយើងចេះអាណិតមេត្តា ឲ្យយើងចេះយកចិត្តដាក់ជាមួយបងប្អូនឯទៀតៗ ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាដើមឈើមួយយ៉ាងធំបំផុត ឲ្យមនុស្សទាំងអស់អាចជួបជុំគ្នាដោយដឹងថានៅកន្លែងនេះ ខ្ញុំមានបទពិសោធន៍អំពីសេចក្តីសុខសាន្ត អំពីសេចក្តីស្រឡាញ់មកជាបងប្អូន និងអំពីព្រះហឫទ័យប្រណីសណ្តោស ការលើកលែងទោសពីព្រះជាម្ចាស់តែម្តង។ យើងធ្វើយ៉ាងម៉េច ដើម្បីឲ្យព្រះសហគមន៍របស់យើង ដែលថ្ងៃនេះពោពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ទៅជាព្រះសហគមន៍របស់ព្រះគ្រីស្ត មានន័យថាទៅជាសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលលូតលាស់នៅគ្រប់ទីកន្លែងដូចដើមឈើលូតលាស់នៅលើថ្ម ដោយសារជីវិតឈ្នះថ្ម ឈ្នះអំពើបាប និងឈ្នះសេចក្តីស្លាប់។ អាម៉ែន៕